CAMBODIA'S NO.1 WOMEN'S LIFESTYLE MAGAZINE

FULLY BILINGUAL IN KHMER & ENGL

# LADIES

ឡេឌី

ខែ កញ្ញា ២០១៤ | SEPTEMBER 2014



## The Next BIG Trends

**31** *Pages of Beauty Tips & Fashion Trends*

**EXCLUSIVE COVERAGE**

Phnom Penh Designers Week

Cineplex Red Carpet

Glamazon: Abyss

**LOV**

រឿងពិត

ស្នេហាសម័យទំនើ

**LIZA OWE**

បង្ហើបប្រាប់រឿង

**WEDDIN**

ការណែនាំពីអ្នកជំនា

## Daphnée Lucen

## លើសពីរូប

## សម្រស់របស់នា

Beyond Her Bea

**SE**

ស្ត្រី 6

នាក់លាតត្រដ

រឿង

TIGER MEDIA

MG000002103*

8.000 រៀល

**PLUS:**

**STYLE BEAUTY FASHION HEALTH**




# BEHIND THE SCENES

តារាក្របមុខនាង Daphnée Lucenet បានមកដល់ស្ទូឌីយោរបស់យើងជាលើកទីពីរហើយ បានត្រៀមខ្លួនជាស្រេចដើម្បីថតរូបដ៏ស្រស់ស្អាតជាមួយអ្នកថតរូបលោក Balazs Maar។ នាងបានជជែកលេងជាមួយអ្នកស្ទាយលីស Reynier Albello និងអ្នកផាត់មុខរបស់នាង គ្រាដែលត្រៀមខ្លួនបញ្ចេញសម្រស់មុខកាមេរ៉ា។ ទាំងស្រស់ស្អាត និងឆ្លាតវៃនាងរីករាយ ដើម្បីធ្វើការ និងលាតត្រដាងពីជីវិតពិតដល់យើងទាំងអស់គ្នា។

Cover girl Daphnée Lucenet arrived at our studios for the second time in high spirits and ready to work on the cover shoot along with photographer Balazs Maar. She chatted amicably with stylist Reynier Albello and her makeup artist while getting ready to pose for the camera. Both extremely intelligent and stunning she was a pleasure to work with and get to know.

## SEPTEMBER 2014 MOOD BOARD






VALENTINO
Cape-style silk-crepe mini dress
٢,٢٧٩,٢٤$



NINA RICCI
collections fall winter ١٥-٢٠١٤



DIANE VON FURSTENBERG
Benett Two leopard-print stretch-silk straight-leg pants
٣٥٤,٦٦$



HERVÉ VAN DER STRAETEN
Hammered gold-plated cuff
٤٣٣,٤٨$



GIANVITO ROSSI
Leather sandals
٦١٧,٨٠$









CREDITS
*Cover Star:* DAPHNEE LUCENET
*Photography:* BALAZS MAAR
*Styling:* REYNIER ABELLO
*Hair and Make-up:* DEE'S STUDIO FOR COVER, NYX COSMETICS FOR INSIDE PAGES

## ទស្សនៈយល់ឃើញរបស់
### *Daphnée Lucenet*

# the many sides of Daphnée Lucenet

**photographs by balazs maar**
**hair and make-up by dee daniel | wardrobe by the showroom**

ពណ៌សម្បុរស្បែកស្រស់ថ្លានិងមានរាងមាំមួន និងមានចិត្តទូលាយនិងរួសរាយរាក់ទាក់ នាង Daphnée Lucenet ជាមនុស្សមានចិត្តស្មោះត្រង់ ចូលចិត្តនិយាយតែការពិត ដែលទាំងនេះគឺជាគុណសម្បត្តិដ៏ល្អប្រពៃនិងដ៏កម្ររបស់នាង។ នៅអំឡុងដំណើរកម្សាន្តដ៏ឆាប់រហ័សរបស់នាងមកកាន់កម្ពុជា (នាងជាជនជាតិបារាំង) Daphnée ក៏ត្រូវបានគេស្គាល់ឈ្មោះថា Dash Luce ផងដែរ ចំណាយពេលជជែកជាមួយក្រុមការងាររបស់យើងអំពីការងារម៉ូដែល គឺជាអ្វីដែលធ្វើឱ្យនាងមានអារម្មណ៍ស្រស់ស្រាយ និងចាប់អារម្មណ៍ជាខ្លាំងចំពោះរាជាណាចក្រអច្ឆរិយៈមួយនេះ។

**Complex and multidimensional yet uncomplicated and personable, Daphnée Lucenet's honesty and candor are rare, beautiful qualities to come across in an industry that rarely bothers to perforate beneath the skin. In the middle of her Cambodian whirlwind tour (she is a resident of France) Daphnée, also known as Dash Luce takes time to talk with our team about modeling, what makes her feel alive and her fascination with The Kingdom of Wonder.**

**ឈ្មោះ Dash Luce បានមកពីណា ?**

ឈ្មោះ Dash គឺជាឈ្មោះដើមដែលខ្ញុំបានទទួល នៅពេលខ្ញុំមានអាយុ១០ឆ្នាំ ជារឿងមួយដ៏គួរឱ្យអស់សំណើច ប៉ុន្តែក៏ជារឿងសម្ងាត់ផងដែរ! ចំណុចនេះវាក៏មានន័យថា "rush" ដូច្នេះខ្ញុំរក្សាឈ្មោះនេះទុក ពីព្រោះវាស័ក្តិសមនឹងខ្ញុំខ្លាំងណាស់៖ ខ្ញុំតែងតែដើរយ៉ាងលឿន ពីព្រោះការដើរយឺតៗ គឺជាការខ្ជះខ្ជាយពេលវេលាខ្លាំងណាស់សម្រាប់ខ្ញុំ ហើយខ្ញុំមិនចូលចិត្តខ្ជះខ្ជាយពេលវេលារបស់ខ្ញុំទេ ពីព្រោះមានការងារជាច្រើនដែលត្រូវធ្វើ និងឃើញនៅក្នុងពិភពលោកនេះ ដូច្នេះខ្ញុំត្រូវតែប្រើពេលវេលាឱ្យបានសមស្របនោះទេ។ Luce គឺជាឈ្មោះកាត់សម្រាប់ត្រកូលគ្រួសាររបស់ខ្ញុំ និងបានមកពីពាក្យថា "lux" ដែលមានន័យថា "light" ជាភាសាឡាតាំង។ ខ្ញុំបានជ្រើសរើសវាជានិមិត្តរូបសម្រាប់ "ការរៀនយកបទពិសោធន៍" ពីព្រោះការរុករកអ្វីមួយដែលគ្មាននរណាដឹង គឺជាបញ្ហាដែលធ្វើឱ្យជីវិតរបស់ខ្ញុំចាប់អារម្មណ៍និងរំភើបរីករាយ។ នៅទីបំផុត ឈ្មោះពេញពិតប្រាកដរបស់ខ្ញុំបើសរសេរប្រកបគឺមានតួអក្សរដល់ទៅ២០ឯណោះ ហើយឈ្មោះ Dash Luce គឺងាយស្រួលក្នុងការបញ្ចេញសំឡេងនិងចងចាំខ្លាំងណាស់។

**Where did the name Dash Luce come from?**

Well Dash is a nickname I received when I was 10, it's a funny but secret story! The point is, it also means "rush" so I kept it because it suits me quite well: I always walk fast since walking slowly is a real waste of time to me and I hate wasting my time because there is too much to do and see in the world not to use time properly. Luce is just short for my family name and comes from the word "lux" which means "light" in Latin. I have picked it up as a symbol for "learning experience" because exploring the unknown is what keeps my life interesting and exciting. Last but not the least, my real full name is 20 letters long, Dash Luce is way easier to pronounce and remember.

**សព្វថ្ងៃនេះ តើអ្វីទៅគឺជាបទពិសោធន៍នៃការធ្វើដំណើរខុសប្លែកពីធម្មតាបំផុត ដែលអ្នកធ្លាប់បានជួប ?**

បទពិសោធន៍ដ៏អាក្រក់បំផុតរបស់ខ្ញុំ គឺពិតជាការហ្វឹកហាត់ក្បាច់កុងហ្វូពេញម៉ោង នៅតំបន់ចុងកាត់មាត់ញកនៃប្រទេសចិនអស់រយៈពេល៤ខែ! វាមិនមែនជាកន្លែងសម្រាប់ថ្ងៃឈប់សម្រាកទេ ប៉ុន្តែគឺជាកន្លែងស្ងប់ស្ងាត់ខាងផ្លូវចិត្ត។ ខ្ញុំបានធ្វើដំណើរគ្រប់ច្រកល្ហកដោយខ្លួនឯង ដោយប្រកាន់យកគោលការណ៍ដ៏តឹងរឹងដែលខ្ញុំរួចរស់ជីវិត ដូច្នេះបានអនុញ្ញាតឱ្យខ្លួនខ្ញុំផ្តោតតែទៅលើការរៀនក្បាច់គុន និងការធ្វើសមាធិតែឯង។ យើងគ្មានម៉ាស៊ីនកម្តៅ និងមានតែទឹកត្រជាក់ដើម្បីងូតតែប៉ុណ្ណោះ (វាមានសីតុណ្ហភាពក្រោម២០អង្សាសេ នៅរដូវរងា!) ដូច្នេះខ្ញុំត្រូវតែរត់ និងធ្វើអាពុយអាវ៉ង់ មុនពេលចូលដំណេកដើម្បីឱ្យឡើងកម្តៅ។ ខ្ញុំតែងតែភ្ញាក់ពីដំណេកនៅម៉ោង៥កន្លះ ជាពេលដែលយើងត្រូវរត់នៅភ្នំនោះរួចធ្វើលំហាត់ប្រាណពេញមួយថ្ងៃ។

ជួនកាលសាច់ដុំរបស់ខ្ញុំឈឺចាប់ជាខ្លាំង ធ្វើឱ្យខ្ញុំភ្ញាក់នៅពាក់កណ្តាលយប់ក៏មានដែរ។ យើងក៏ញុំាទឹកក្តៅឧណ្ហៗអស់ជាច្រើនដើម្បីកុំឱ្យរងា ហើយវាធ្វើឱ្យខ្ញុំដឹងច្បាស់ថាតើជីវិតរបស់ខ្ញុំងាយស្រួលដល់កម្រិតណា ពេលត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំក៏បានចាកចេញជាមួយនឹងគោលបំណងដែលអាចបំបែកឥដ្ឋមួយដុំដោយដៃទទេបាន ក្រោយការហ្វឹកហាត់រយៈពេល២ខែ ដោយគិតថា ប្រសិនបើខ្ញុំអាចដោះស្រាយបញ្ហាប្រឈមផ្ទាល់ខ្លួនបាន ខ្ញុំអាចសម្រេចអ្វីៗនៅក្នុងជីវិតបាន។ ខ្ញុំត្រូវតែចំណាយពេលវេលាកែលម្អវារាល់ថ្ងៃ ធ្វើឱ្យដៃរបស់ខ្ញុំរឹងមាំ ដោយដាល់ដើមឈើរយៈពេល២ម៉ោងក្នុងមួយថ្ងៃនៅពេលទំនេរ ហើយនៅថ្ងៃមួយទីបំផុតខ្ញុំក៏បានសម្រេចគោលបំណងរបស់ខ្ញុំប្រាកដមែន នេះមិនដោយសារការខិតខំធ្វើការងារនិងការប្តេជ្ញាចិត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារខ្ញុំមានគ្រូម្នាក់ដ៏ពូកែ។

អ្នកប្រហែលជាគិតថាខ្ញុំឆ្កួតហើយមើលទៅ ប៉ុន្តែការហាត់ក្បាច់កុងហ្វូនៅចិន គឺជាក្តីសុបិនដ៏ធំបំផុតរបស់ខ្ញុំ (ខ្ញុំស្រឡាញ់ពេញចិត្ត

# DAPHNÉE LUCENET

# ភាសាតស្ត្រី



Photograph by Balazs
Hair and Make-up by Dee
Wardrobe by The Sho

## “ទោះបីនាងជាអ្នកស្នេហាតន្ត្រីក៏ដោយ ក៏នាងអាចធ្វើឱ្យមនុស្សចេះសាមគ្គីគ្នា ដោយមិនគិតពីប្រវត្តិទាក់ទងនឹងវប្បធម៌និងសេដ្ឋកិច្ចសង្គមឡើយ។”

កញ្ញាDaphnéeLucenetនិងខ្ញុំបានជជែកគ្នាដោយក្តីរីករាយ ខណៈពេលនាងកំពុងតែរង់ចាំក្រុមអ្នកធ្វើស្តាយល៍មកដល់ដើម្បីរៀបចំខ្លួនឱ្យនាងថតរូបនៅថ្ងៃនោះ។ ស្តាយល៍ហ៊ីបហបរបស់នាង ត្រូវបានបិទបាំងដោយទឹកមុខបែបស្ងាត់ស្ងៀម ហើយផ្ទៃមុខដែលមិនបានលាបផាត់មុខក្រែមម្សៅអ្វីទាំងអស់ប្រែជាស្រស់ប្រិមប្រិយពោរពេញទៅដោយក្តីអំណរ។ នៅពេលនិយាយ នាងបង្ហាញនូវភាពទាក់ទាញពីធម្មជាតិហើយបើទោះជានាងប្រកបដោយភាពរឹងប៉ឹង និងមានទស្សនៈច្បាស់លាស់ចំពោះអ្វីដែលនាងចង់ធ្វើនាពេលអនាគតដ៏ខ្លីក៏ដោយក៏ឫក្សាពាររបស់នាងមិនរឹងត្អឹងឡើយ ពាក្យសម្តីរបស់នាងទៀតសោតក៏ពីរោះពិសាផងដែរនាងគឺជាមនុស្សម្នាក់ដែលចង់ឱ្យមនុស្សមួយក្រុមធំចេះរួមសាមគ្គីគ្នាតាមរយៈភាសាតន្ត្រីសកល។

ខ្ញុំសាកសួរអំពីជីវប្រវត្តិរបស់នាង និងដឹងថាម្តាយរបស់នាងគឺជាជនជាតិកម្ពុជា បានមកដល់ប្រទេសបារាំងនៅឆ្នាំ១៩៨០ ហើយបានជួបជាមួយឪពុករបស់នាង (ជនជាតិបារាំង) នៅទីនោះ។ Daphnée បានកើតនិងធំដឹងក្តីនៅទីក្រុងប៉ារីស ព្រមទាំងមានអារម្មណ៍កាន់តែរឹងមាំឡើងៗជាមួយនឹងបេតិកភណ្ឌរបស់ខ្មែរ កាលពីពេលកន្លងទៅ។ទោះបីម្តាយរបស់នាង មិនបានបង្រៀនភាសាខ្មែរដល់នាងក្តីនៅពេលធំដឹងក្តី នាង Daphnée និយាយថា នាងកំពុងព្យាយាមរៀនអាននិងសរសេរភាសាខ្មែរព្រមទាំងហាត់បញ្ចេញសំឡេងឱ្យបានល្អ ហើយនាងថែមទាំងទាញយកកូនសៀវភៅពណ៌បៃតងតូចមួយក្បាលចេញមក និងចង្អុលពាក្យមួយចំនួន(សរសេរជាភាសាខ្មែរ) ដែលនាងបានដាក់តាមជាប់នឹងខ្លួននៅពេលធ្វើដំណើរ។

អំឡុងពេលដ៏ខ្លីនៅកម្ពុជា កញ្ញា Daphnée បានច្រៀងនៅហាងខារ៉ាអូខេនានាជាមួយនឹងសាច់ញាតិរបស់នាង បានសម្តែងក្នុងកម្មវិធីហ្វេហ្វិន និងថតរូបឱ្យក្រុមបណ្ណាធិការ ដូច្នេះខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងណាស់ដោយបានដឹងថា នាងមានជំនាញខាងព័ត៌មានវិទ្យា និងបានធ្វើជាអ្នកហាត់ការនៅធនាគារទៀតផង។ ពេលសិក្សានៅសាកលវិទ្យាល័យដំបូង នាងបានទៅលេងនៅកម្ពុជាជាផ្នែកមួយនៃគម្រោងដែលជួយតម្លើងបន្ទះស្រូបពន្លឺព្រះអាទិត្យ នៅភូមិក្រីក្រមួយក្បែរខេត្តសៀមរាប ធ្វើឱ្យនាងទទួលបានបទពិសោធន៍ជាច្រើន នាងមិនចង់បាននូវការតបស្នងសងគុណពីអ្នកភូមិឡើយ ហើយនាងក៏មិនដែលគិតឱ្យអ្នកភូមិត្រូវតែយករង់ភ្លេងមកប្រគំទទួលស្វាគមន៍នាងនោះដែរ។ ទោះបីនាងជាអ្នកស្នេហាតន្ត្រីក៏ដោយ ក៏នាងអាចធ្វើឱ្យមនុស្សចេះសាមគ្គីគ្នា ដោយមិនគិតពីប្រវត្តិរូបទាក់ទងនឹងវប្បធម៌និងសេដ្ឋកិច្ចសង្គមនោះឡើយ។

កញ្ញា Daphnée ក្រោយមកមានទស្សនៈយ៉ាងជាក់ច្បាស់ទាក់ទងទៅនឹងអ្វីដែលនាងចង់បង្កើត គឺមហោស្រពតន្ត្រីខ្មែរដែលបានភ្ជាប់គ្នាទៅនឹងគម្លាតវ័យវប្បធម៌និងហិរញ្ញវត្ថុដោយធ្វើឱ្យអ្នកទស្សនារីករាយ និងមានក្តីអំណរ។ជំហានដំបូងគឺត្រូវបង្កើតជាសមាគមមួយ មានមនុស្សមួយក្រុមដែលអាចជួយប្រែក្លាយទស្សនៈរបស់នាងឱ្យក្លាយជាការពិតបាន ហើយនេះគឺជារបៀបដែល Khmer Vibration ចង់បាន។ ដំបូងឡើយព្រឹត្តិការណ៍ (មហោស្រពតន្ត្រី) នេះ ត្រូវរៀបចំធ្វើនៅកម្ពុជា ប៉ុន្តែត្រូវមានការរៀបចំភស្តុភារនៃមហោស្រពតន្ត្រីក្នុងស្រុកមួយ រីឯនៅប្រទេសបារាំងវិញ ការងារអ្វីៗមិនងាយស្រួលដូចមាត់ចេះតែថានោះទេ ហើយ Daphnée ត្រូវតែសម្របសម្រួលផែនការណ៍របស់នាងឡើងវិញ។ "ខ្ញុំបានដឹងច្បាស់ថា ខ្ញុំមិនអាចធ្វើអ្វីៗបានល្អនោះទេ ខណៈពេលនៅទីក្រុងប៉ារីស វាពិតជាពិបាកខ្លាំងណាស់ក្នុងទទួលបានកុងត្រាដ៏ត្រឹមត្រូវ និងដឹងនូវអ្វីដែលកំពុងកើតឡើង។ ដូច្នេះ ផ្ទុយពីនេះ ខ្ញុំបានរៀបចំមហោស្រពតន្ត្រីដ៏ធំមួយនៅទីក្រុងប៉ារីស (កាលបរិច្ឆេទដ៏ជាក់លាក់ គឺត្រូវបានប្រកាសឱ្យដឹង ប៉ុន្តែវានឹងរៀបចំធ្វើឡើងនៅខែវិច្ឆិកា) ការនោះនឹងជួយប្រមូលផ្តុំពលរដ្ឋកម្ពុជា និងជួយ ទាក់ទាញការចាប់អារម្មណ៍ចំពោះវប្បធម៌និងបេតិកភណ្ឌរបស់ខ្មែរ។មានយុវវ័យជាច្រើនដូចជាខ្ញុំដែរ ដែលមានចំណាប់អារម្មណ៍ខ្លាំងចំពោះប្រទេសនេះ និងចំពោះការស្វែងយល់បន្ថែមអំពីប្រទេសនេះ ដូច្នេះពិតជារំភើបខ្លាំងណាស់"។

នៅពេលយើងជជែកគ្នាបន្ថែមទៀត កាន់តែបង្ហាញច្បាស់ចំពោះខ្ញុំនិងធ្វើឱ្យខ្ញុំចង់ដឹងច្រើនថែមទៀតអំពីនាង ភ្នែករបស់នាងចាំងពន្លឺផ្លេកៗ នៅពេលនាងប្រាប់ខ្ញុំថា Khmer Vibration ពិតជាបានទាក់ទាញតន្ត្រីករដែលមិនមែនជាពលរដ្ឋកម្ពុជា ប៉ុន្តែពួកគេចាប់អារម្មណ៍ក្នុងគម្រោងនេះ ក៏ដូចជាអ្នកសាទរឯទៀតផងដែរ ដែលមានឆន្ទៈជួយធ្វើអ្វីៗក្រៅពីសែងប្រអប់ធ្ងន់ៗឡើងលើឆាក និងសម្តែង។ បន្ទាប់ពីមហោស្រពតន្ត្រីខែវិច្ឆិកាបានប្រារព្ធធ្វើរួចរាល់ ការចាត់ចែងនឹងផ្តល់ទៅឱ្យអង្គការរបស់កម្ពុជា ដែលផ្តោតទៅលើការផ្សព្វផ្សាយសិល្បៈក្នុងចំណោមយុវវ័យ ពោលគឺនាងកំពុងតែគិតទៅដល់សិល្បៈសៀក PHARE Circus និង Tiny Toones។

នេះនឹងមិនមែនជាលើកដំបូងទេ ដែលនាងបានបង្កើតអ្វីមួយដើម្បីឱ្យពលរដ្ឋខ្មែរចេះរួមសាមគ្គីគ្នា។ នាងបង្ហាញខ្ញុំនូវខ្សែវីដេអូមួយដែល Khmer Vibration បានបញ្ចូលជាមួយគ្នា ដោយរៀបរាប់ពីការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរនៅប៉ារីស ដែលទាំងពលរដ្ឋខ្មែរ និងទាំងអ្នកមិនមែនជាពលរដ្ឋខ្មែរបានចូលរួមរាំ ច្រៀង ញ៉ាំ និងផឹកជាមួយគ្នា។ ជាមួយនឹងបុគ្គលិកដែលមោះមុតក្នុងការងារប្រកបដោយក្តីអំណរ កញ្ញា Daphnée Lucenet ពិតជានឹងមានសមត្ថភាពធ្វើឱ្យមហោស្រពមួយនេះទទួលជោគជ័យ។ នៅពេលយើងលាគ្នា (អ្នកធ្វើស្តាយល៍របស់នាងឥឡូវបានមកដល់ល្មម ហើយភ្នែកពណ៌ត្នោតធំៗរបស់នាងធ្មេចបើកៗ នៅពេលដែលសក់ដ៏វែងអន្លាយមួលគ្របាញ់ចូលគ្នាបានប៉ះនឹងភ្នែក) ខ្ញុំជឿជាក់ថា ការរៀបចំរបស់នាងនឹងទទួលបានជោគជ័យខ្លាំងឡើងៗ ហើយនាងនឹងថែមទាំងទទួលបានការចាប់អារម្មណ៍ឧស្សាហកម្មជាច្រើនលើសពីវិស័យមួយនេះផងដែរ៕





Photograph by Balazs Maar | Hair and Make-up by Dee Daniel | Wardrobe by The Showroom

# Daphnée Lucenet
# THE LANGUAGE OF MUSIC

Daphnée Lucenet and I chat amicably while she is waiting for her team of stylists to arrive and prep her for the day's photo shoot. Her definite hip-hop style is masked by her low-key appearance and her makeup-free face shines bright with enthusiasm. As she speaks, a certain charisma is revealed. Though she is decidedly very strong and possesses a clear vision of what she wants to create in the near future, there is no harshness to her manner, no sharp edges or off-putting seriousness to any of her words; she is simply someone that wants to bring a large group of people together through the universal language of music.

I ask her about her background and find out that her mother, a Cambodian woman, arrived in France in 1980 and met her father (a Frenchman) soon after. Daphnée was born and raised in Paris and felt the affinity with her Khmer heritage become stronger and stronger with the passing of time. Though her mother didn't teach her the Cambodian language while growing up, Daphnée says that she is trying her best to learn how to read and write Khmer as well as improve her accent; she even pulls out a small green notebook and points to several words (written in Khmer, no less) that she has picked up during this trip.

During her short stint in the Kingdom this time around, Daphnée has been singing at

Karaoke joints with her relatives, has appeared in a Fashion Show and is posing for one of our editorials, *and* our cover so I am very surprised to learn that she actually majored in IT and has done banking internships. During the early stages of her University studies she paid a visit to Cambodia as part of a project that helped install solar panels in an impoverished village close to Siem Reap. The experience touched her profoundly; she couldn't have anticipated the generosity and kindness of the villagers, nor could she have guessed that they would actually have an orchestra playing upon their arrival as a sign of welcome. Although she had always been a lover of music, its power to unite people regardless of their cultural or socio-economic background had never been as piercingly evident as that moment.

Daphnée finally had a strong, clear vision for what she wanted to create: a Khmer music festival that bridged the age, culture and financial gap, injecting its audience with joy and enthusiasm. The first step was to create an association, a team of people that would help transform her vision into reality, and this is how *Khmer Vibration* came to be. At first, this event (music festival) was to take place in Cambodia, but organizing the logistics of a local music festival while based in France proved to be easier said than done and Daphnée had to re-adjust her plans. "I realized that I couldn't do things that well while I was in Paris, it was very hard to get the right contacts and really know what was going on. So, instead, I have organized a large Khmer Music Festival in Paris (the exact dates are to be announced, but it will be in the month of November), that will help bring Cambodian people together and help attract attention to Khmer culture and heritage. There are several young people like myself that have a huge amount of interest in the country and in learning more about it, so it's really very exciting!"

As we chat some more, it becomes clear to me just how passionate about this she actually is; her eyes sparkle when she tells me that Khmer Vibration has actually attracted musicians that aren't Cambodian but are interested in the project as well as tons of enthusiasts that are willing to help do anything from carrying heavy boxes to getting up on stage and performing. After the November music festival has taken place, all of the proceeds will go to a Cambodian organization that is focused on promoting arts among youth as a way of empowerment for which she is considering both the PHARE Circus and Tiny Toones.

This will not be the first time she has organized something to bring Khmer people together. She shows me a video Khmer Vibration has put together, depicting the Khmer New Year's celebration in Paris, where both Khmer and non-Khmer people alike gathered to dance, sing, eat and drink. With such enthusiastic, committed staff, Daphnée Lucenet will surely be able to pull off an extraordinary festival. As we part (her stylists have now arrived and her big brown eyes wince at the pain every time her long hair is twisted into a knot) I am certain that her organization will go from strength to strength and she will soon be making waves in more Industries than one.



*"Although she had always been a lover of music, its power to unite people regardless of their cultural or socio-economic background had never been so piercingly evident"*